## ស្ថានភាពអតិផរណានៅខែធ្នូ ឆ្នាំ២០១៧

### ក/ អតិផរណាក្នុងប្រទេស

សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅរាជធានីភ្នំពេញក្នុងខែធ្នូ ឆ្នាំ២០១៧ បានកើនឡើងក្នុងអត្រា **0,៤%** ធៀបនឹងខែមុន និងកើនឡើង **២,២%** បើធៀបនឹង១២ខែមុន។

ក្នុងឆ្នាំ២០១៧ អតិផរណាចុងឆ្នាំ (Year on Year) មានអត្រា ២,២% ទាបជាងឆ្នាំ២០១៦ដែលមានអត្រា ៣,៩% និងមធ្យមប្រចាំឆ្នាំ (Year average) មានអត្រា ២,៩% ទាបជាងឆ្នាំ២០១៦ ដែលមានអត្រា ៣%។ តាមការសង្កេត អតិផរណាមាននិន្នាការកើនឡើងគួរឱ្យកត់សម្គាល់ក្នុងឆមាសទី១ (កំណើនជាមធ្យម ៣,៥%) ដោយសារការកើនឡើងថ្លៃម្ហូបអាហារ និងសម្លៀកបំពាក់ បូករួមទាំងការងើបឡើងវិញនៃថ្លៃប្រេងសាំង និងម៉ាស៊ូត ផងដែរ។ ប៉ុន្តែចាប់ពីដើមឆមាសទី២ កំណើនអតិផរណាបានថយចុះមកវិញដោយសារការថមថយកំណើននៃថ្លៃក្រុមទំនិញមួយចំនួនដូចជា សម្លៀកបំពាក់, ភេសជ្ជៈមានជាតិស្រវឹងនិងថ្នាំជក់, គ្រឿងសង្ហារឹម, សុខាភិបាល និងជាពិសេសថ្លៃក្រុមទំនិញម្ហូបអាហារដូចជា សាច់, ត្រី, បន្លែ និងផ្លែឈើ ដែលមានមេគុណប្រមាណជាង ៤៤% នៃកន្ត្រកសន្ទស្សន៍ថ្លៃទំនិញទាំងអស់។

សរុបមក ក្នុងឆ្នាំ២០១៧ អត្រាអតិផរណារបស់ប្រទេសកម្ពុជានៅតែរក្សាបានស្ថានភាពល្អ គឺស្ថិតនៅក្នុងកម្រិតមួយដែលអាចគ្រប់គ្រងបាន, អាចជួយជំរុញសកម្មភាពផលិតកម្មក្នុងស្រុក និងរួមចំណែកក្នុងការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចផងដែរ។

| តារាង ១÷ បម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញទាំង១២ក្រុម (%) | | |
|---|---|---|
| | ធៀបនឹងខែមុន | ធៀបនឹង១ឆ្នាំមុន |
| **មុខទំនិញគ្រប់មុខ** | **+0,៤** | **+២,២** |
| ១-អាហារនិងភេសជ្ជៈមិនមានជាតិស្រវឹង | +0,២ | +១,៩ |
| ២-ភេសជ្ជៈមានជាតិស្រវឹងនិងថ្នាំជក់ | -0,៣ | +0,៣ |
| ៣-សម្លៀកបំពាក់និងស្បែកជើង | -0,១ | +១,៥ |
| ៤-ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន | +0,៧ | +0,៦ |
| ៥-គ្រឿងសង្ហារឹម សម្ភារៈប្រើប្រាស់ | +0,២ | +0,២ |
| ៦-សុខាភិបាល | 0,0 | +១,១ |
| ៧-ការដឹកជញ្ជូន | +១,៤ | +៤,៤ |
| ៨-គមនាគមន៍ | -0,៣ | -0,៧ |
| ៩-ការកំសាន្ត និងវប្បធម៌ | +0,១ | -0,៨ |
| ១0-ការសិក្សា | 0,0 | -0,៧ |
| ១១-ភោជនីយដ្ឋាន | +0,៧ | +៧,៦ |
| ១២-ទំនិញ និងសេវាកម្មផ្សេងៗ | +0,៦ | +២,៩ |

| តារាង ២÷ បម្រែបម្រួលសន្ទស្សន៍ថ្លៃម្ហូបអាហារសំខាន់ៗ (%) | | | | | | |
|---|---|---|---|---|---|---|
| មុខទំនិញ | ធៀបខែមុន | | | ធៀបនឹងឆ្នាំមុន | | |
| | ២០១៧ | | | ២០១៧ | | |
| | តុលា | វិច្ឆិកា | ធ្នូ | តុលា | វិច្ឆិកា | ធ្នូ |
| អង្ករ | +០,១ | +០,៣ | +០,១ | +២,២ | +២,០ | +១,៦ |
| សាច់គោ | -០,១ | +០,៤ | +០,៨ | +២,៤ | +២,៥ | +៣,០ |
| សាច់មាន់ | +០,៤ | ០,០ | -០,៦ | +១,២ | +១,២ | +០,៣ |
| សាច់ទា | +០,៦ | +០,៣ | +០,៣ | +០,៧ | +០,៩ | +០,៦ |
| សាច់ជ្រូក | -០,៧ | +០,៤ | -០,៦ | +០,៥ | +១,០ | -០,៣ |
| ត្រីទឹកសាប និង ត្រីទឹកសមុទ្រ | -០,៨ | +១,២ | ០,០ | +៤,៣ | +៤,៩ | +៤,៥ |
| ក្នុងនោះត្រីស្រស់ | -១,១ | +១,៤ | ០,០ | +៤,១ | +៥,២ | +៤,៩ |
| ផ្លែឈើ | ០,០ | -០,៣ | +០,៨ | ០,០ | +០,៨ | +១,០ |
| ផ្លែឈើស្រស់ | ០,០ | -០,៤ | +១,០ | -០,៨ | ០,០ | +០,៣ |
| បន្លែ | -០,៩ | ០,០ | +០,៦ | -០,១ | -១,៣ | -០,៩ |
| បន្លែជាស្លឹក | -១,៣ | +១,៣ | +១,៦ | -១,៣ | -១,៧ | -០,៧ |
| បន្លែជាផ្លែ | -០,១ | -១,៥ | -០,១ | -១,៩ | -៤,៥ | -៤,០ |

## ១/ អតិផរណាប្រចាំឆ្នាំរបស់ប្រទេសមួយចំនួន

| តារាង ៣÷ អតិផរណាប្រចាំឆ្នាំ (គិតជា %) | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ប្រទេស | ២០១៦ | ២០១៧ | | | | | | | | | | | |
| | ធ្នូ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
| ប្រទេសកម្ពុជា | 3.9 | 4.4 | 4.0 | 4.3 | 3.2 | 2.5 | 2.3 | 2.3 | 2.6 | 2.7 | 2.1 | 2.3 | 2.2 |
| ប្រទេសវៀតណាម | 4.74 | 5.2 | 5.0 | 4.7 | 4.3 | 3.2 | 2.5 | 2.5 | 3.4 | 3.4 | 3.0 | 2.6 | 2.6 |
| ប្រទេសថៃ | 1.13 | 1.6 | 1.4 | 0.8 | 0.4 | -0.04 | -0.05 | 0.2 | 0.3 | 0.9 | 0.9 | 0.99 | 0.78 |
| ប្រទេសម៉ាឡេស៊ី | 1.8 | 3.2 | 4.5 | 5.1 | 4.4 | 3.9 | 3.6 | 3.2 | 3.7 | 4.3 | 3.7 | 3.4 | 3.5 |
| ប្រទេសឥណ្ឌូនេស៊ី | 3.02 | 3.5 | 3.8 | 3.6 | 4.2 | 4.3 | 4.4 | 3.9 | 3.8 | 3.7 | 3.6 | 3.3 | 3.6 |
| ប្រទេសហ្វីលីពីន | 2.6 | 2.7 | 3.3 | 3.4 | 3.4 | 3.1 | 2.8 | 2.8 | 3.1 | 3.4 | 3.5 | 3.3 | 3.3 |
| ប្រទេសចិន | 2.1 | 2.5 | 0.8 | 0.9 | 1.2 | 1.5 | 1.5 | 1.4 | 1.8 | 1.6 | 1.9 | 1.7 | 1.8 |
| ប្រទេសកូរ៉េខាងត្បូង | 1.3 | 2.0 | 1.9 | 2.2 | 1.9 | 2.0 | 1.9 | 2.2 | 2.6 | 2.1 | 1.8 | 1.3 | 1.5 |
| ប្រទេសជប៉ុន | 0.3 | 0.4 | 0.3 | 0.2 | 0.4 | 0.4 | 0.4 | 0.4 | 0.7 | 0.7 | 0.2 | 0.6 | 1.0 |

ប្រភពទិន្នន័យ

(១) ប្រទេសកម្ពុជា គឺពីវិទ្យាស្ថានជាតិស្ថិតិ(NIS)

(២) ប្រទេសផ្សេងៗទៀត គឺពីគេហទំព័រ http://www.tradingeconomics.com;

**<u>កំណត់សម្គាល់</u>**

ការចងក្រងសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (CPI) នៅភ្នំពេញ÷

- ថ្លៃទំនិញដែលត្រូវបានជ្រើសរើសមានចំនួន ២៥៩មុខ
- ថ្លៃមុខទំនិញភាគច្រើនត្រូវបានប្រតិបត្តិការប្រមូលពីផ្សារចំនួន ៥
- ជាទូទៅថ្លៃត្រូវបានប្រមូលពីតូបគំរូចំនួន ៤ក្នុងផ្សារនីមួយៗ
- សម្រាប់មុខទំនិញដែលមិនដាក់លក់នៅទីផ្សារ ថ្លៃត្រូវបានប្រមូលពីតូបនៅជិតៗផ្សារ
- សន្ទស្សន៍ថ្លៃនៃមុខទំនិញត្រូវបានចងក្រងតាមមធ្យមរេខាគណិតសាស្ត្រ (geometric average)

ប្រភព÷ ក្រសួងផែនការ (វិទ្យាស្ថានជាតិស្ថិតិ)

*រៀបចំនិងធ្វើចំណោលដោយ*

*នាយកដ្ឋានស្ថិតិ និងវិភាគសេដ្ឋកិច្ច*

*អគ្គនាយកដ្ឋានគោលនយោបាយ, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ*